# ល្ខោននិយាយ : រឿងទម្លាយភាពស្ងប់ស្ងាត់

*ឆាំង យូ*

មានភាពស្ងប់ស្ងាត់នៅក្នុងប្រទេសកម្ពុជាជាយូរណាស់មក ហើយទាក់ទងនឹងរបបខ្មែរក្រហម ភាពស្ងប់ស្ងាត់ដែលបានបន្សល់ទុកជាច្រើនទសវត្សរ៍ ហើយស្ថិតនៅក្នុងចិត្តប្រកបដោយភាពភ័យខ្លាច ការឈឺចាប់ និងរឿងនយោបាយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនដើម្បីបញ្ចប់ភាពស្ងប់ស្ងាត់នេះនៅក្នុងទម្រង់ ជាការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ កម្មវិធីចុះផ្សព្វផ្សាយតាមមូលដ្ឋាន និងការបង្រៀននៅតាមវិទ្យាល័យទូទាំងព្រះរាជាណាចក្រកម្ពុជាពីអំពើប្រល័យពូជសាសន៍ ។ ខណៈពេលដែលយុទ្ធសាស្ត្រនីមួយៗមានសារៈសំខាន់សម្រាប់ដំណើរការធ្វើឲ្យប្រទេសកម្ពុជាប្រសើរឡើង វានៅតែត្រូវការយុទ្ធសាស្ត្រដែលផ្តោតទៅលើផ្នែកអារម្មណ៍ និងស្មារតីទាក់ទងនឹងការផ្សះផ្សានិងការជាសះស្បើយរបួសផ្លូវចិត្ត ។ នេះគឺជាឱកាសដែលសិល្បៈអាចធ្វើវិភាគទានដ៏មានសារៈសំខាន់បំផុត ។ ប្រជាជនកម្ពុជាមានសិល្បៈនៅក្នុងខ្លួន ហើយនេះគឺជាដំណើរជីវិតរបស់ប្រជាជនម្នាក់ ។ ខ្មែរក្រហមបានសម្លាប់អ្នកសិល្បៈជាច្រើន ប៉ុន្តែមិនអាចសម្លាប់ទេពកោសល្យសិល្បៈរបស់ប្រជាជនកម្ពុជា ។ សិស្សគឺជាដួងព្រលឹងរបស់ប្រជាជនកម្ពុជា ។ រឿង «ទម្លាយភាពស្ងប់ស្ងាត់» គឺជាការសម្តែងដ៏អស្ចារ្យបំផុតមួយតាំងពីរបបខ្មែរក្រហមបានដួលរលំនៅក្នុងឆ្នាំ១៩៧៩ ។ វាគឺជាការសម្តែងអំពីប្រជាជនកម្ពុជា ការឈឺចាប់ កំហឹង និងការលើកទឹកចិត្តឲ្យគិតពីអនាគត មិនថាក្នុងកាលៈទេសៈណាក៏ដោយ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមគឺជាប្រជាជនដែលប៉ះទង្គិចផ្លូវចិត្ត រស់នៅក្នុងសង្គមមួយដែលបែកបាក់ ហើយគឺជាមនុស្សដែលវិញ្ញាណកំពុងតែហោះហើរ ។ ខ្ញុំបានរកឃើញវិញ្ញាណនោះរបស់យើងនៅក្នុងការសម្តែងដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ។ ការសម្តែងនេះមានសារៈសំខាន់ចំពោះ ប្រជាជនកម្ពុជាបានទស្សនា និងស្តាប់ ។ វានឹងជួយស្តារសេចក្តីថ្លៃថ្នូរនិងមនុស្សធម៌ ហើយធ្វើឲ្យសីលធម៌របស់យើងកាន់តែប្រសើរឡើង ។ វាក៏នឹងជួយឲ្យកូនចៅរបស់យើងដឹងពីប្រទេសយើងកាន់តែច្បាស់ ។ ខ្ញុំសង្ឃឹមថាការសម្តែងនៅពេលអនាគតនឹងដូចគ្នាទៅនឹងការសម្តែងនេះ គឺវានឹងមានតួនាទីសំខាន់ក្នុងការស្តារសង្គមកម្ពុជាសារឡើងវិញ ។